ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សភាពាណិជ្ជកម្ម រាជធានីភ្នំពេញ
ចូល
លេខៈ 350
ថ្ងៃទី 27/6/16 ម៉ោង 3h
បញ្ជូន

អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា

លេខ : ១០៥៣/១៦ អ គ រ

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែ មិថុនា ឆ្នាំ ២០១៦

**ជម្រាបមក**

- **លោក លោកស្រី ប្រធាននាយកដ្ឋាន សាខា និងការិយាល័យគយនិងរដ្ឋាករ**
- **លោក លោកស្រីជាមន្ត្រីតម្លៃគិតពន្ធគយ**

**កម្មវត្ថុ ÷** ការកែសម្រួលកម្រិតសមត្ថកិច្ចនៃការផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ដោយមន្ត្រីគយនៅតាមអង្គភាពគយនិងរដ្ឋាករមូលដ្ឋាននានា ដែលមិនទាន់មានមន្ត្រីតម្លៃគិតពន្ធគយប្រចាំការ។

**យោង ÷** - យោងច្បាប់ស្តីពីគយដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧

- សេចក្តីណែនាំលេខ ០០១ សហវ ចុះថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០០០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការបញ្ជាក់បន្ថែមនិងការកែសម្រួលនីតិវិធីនៃការកំណត់តម្លៃគិតពន្ធគយ
- លិខិតលេខ ៦៣០ គរ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០០៣ របស់ទីចាត់ការគយនិងរដ្ឋាករ ស្តីពីករណីការកែសម្រួលបែបបទគ្រប់គ្រងទំនិញនាំចូលតាមច្រកអន្តរជាតិ និងច្រកតំបន់។

តបតាមកម្មវត្ថុនិងយោងខាងលើ ខ្ញុំសូមជម្រាបជូនលោក លោកស្រីជ្រាបថា ដើម្បីឱ្យស្របតាមការវិវត្តនៃកិច្ចប្រតិបត្តិការធុរកិច្ចអន្តរជាតិនាពេលបច្ចុប្បន្ន និងដើម្បីជម្រុញបន្ថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា សូមធ្វើការកែសម្រួលសមត្ថកិច្ចផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយនៅតាមអង្គភាពគយនិងរដ្ឋាករមូលដ្ឋាន ដែលមិនទាន់មានមន្ត្រីតម្លៃគិតពន្ធគយប្រចាំការ ដូចខាងក្រោម÷

១. ចំពោះវិក្កយបត្រ (សម្រាប់អញ្ញាតប័ណ្ណដឹកជញ្ជូនមួយលេខ) ដែលទំនិញមាន<u>តម្លៃគិតពន្ធគយ</u>មិនលើសពី ៥០០ (ប្រាំរយ) ដុល្លារអាមេរិក ត្រូវផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយ ដោយការិយាល័យគយនិងរដ្ឋាករពាក់ព័ន្ធ។

២. ចំពោះវិក្កយបត្រ (សម្រាប់អញ្ញាតប័ណ្ណដឹកជញ្ជូនមួយលេខ) ដែលទំនិញត្រូវ<u>ជាប់ពន្ធនិងអាករនាំចូល</u>មិនលើសពី ៥០០ ( ប្រាំរយ ) ដុល្លារអាមេរិក ត្រូវផ្ទៀងផ្ទាត់តម្លៃគិតពន្ធគយដោយសាខាគយនិងរដ្ឋាករពាក់ព័ន្ធ។



អាសយដ្ឋានៈ លេខ ៦-៨ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
ទូរស័ព្ទ / ទូរសារ: (៨៥៥-២៣) ២១៤ ០៦៥ / ៧២៥ ១៨៧ / ២១២ ៤៥៧ / E-mail: info-pru@customs.gov.kh

៣. ចំពោះករណីផ្សេងពីនេះ ត្រូវផ្ទៀងផ្ទាត់ដោយមន្ត្រីតម្លៃគិតពន្ធគយដែលប្រចាំការនៅតាមអង្គភាពគយនិងរដ្ឋាករមូលដ្ឋាន ឬនៅនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិ តាមការកំណត់របស់អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

៤. ក្នុងករណីមានបញ្ហាលំបាកផ្នែកបច្ចេកទេសជាយថាហេតុដែលមិនអាចកំណត់តម្លៃគិតពន្ធគយបានតាមចំនុច(ក) និង(ខ) ខាងលើ ការិយាល័យគយនិងរដ្ឋាករ សាខាគយនិងរដ្ឋាកខេត្ត ឬបុគ្គលពាក់ព័ន្ធអាចស្នើសុំការណែនាំពីនាយកដ្ឋានផែនការ បច្ចេកទេស និងកិច្ចការអន្តរជាតិនៃអគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោក លោកស្រី ចាត់ចែងផ្សព្វផ្សាយឲ្យបានទូលាយ និងអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់តាមខ្លឹមសារនេះ ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០១៦ តទៅ។

សូមលោក លោកស្រី ទទួលនូវការស្រលាញ់រាប់អានពីខ្ញុំ។

**អគ្គនាយក**

**អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា**

បណ្ឌិត គុណ-ញឹម

**ចម្លងជូន៖**

- ខុទ្ទកាល័យឯកឧត្តមទេសរដ្ឋមន្ត្រី
  រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
  "ដើម្បីជូនជ្រាប"
- សភាពាណិជ្ជកម្មកម្ពុជា"ដើម្បីជូនជ្រាប និងសហការផ្សព្វផ្សាយ"
- ឯកសារ-កាលប្បវត្តិ